**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...១៧២៤.....អពដ

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ តុលា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបង់ពន្ធអាជីវកម្មលើសំណង់បុរី ផ្ទះល្វែង វីឡា ឬអគារសម្រាប់លក់

អនុលោមតាមស្មារតីអង្គប្រជុំនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ជាមួយម្ចាស់សំណង់បុរី ផ្ទះល្វែង វីឡា ឬអគារ និងចំណារឯកភាពរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ លើលិខិតលេខៈ១១២៦ អពដ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដំណឹងដល់ម្ចាស់សំណង់បុរី ផ្ទះវីឡា ឬអគារសម្រាប់លក់ទាំងអស់ ដូចខាងក្រោម÷

១-ម្ចាស់សំណង់ដែលបានបើកការដ្ឋានសាងសង់និងលក់ចាប់ពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ត្រូវទិញគ្រឿងសំណង់ពីអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(របបពិត) ដើម្បីទទួលបានឥណទានលើអាករជាតុចូលសម្រាប់កាត់កងជាមួយអាករលើធាតុចេញនៅពេលលក់ចេញ។

២-ការសាងសង់ផ្ទះល្វែង វីឡា ឬអគារសម្រាប់លក់ទាំងអស់ត្រូវបូកបន្ថែមអាករលើតម្លៃបន្ថែម១០% (ភាគរយ)លើតម្លៃសំណង់ តាមមាត្រា៦៤ នៃច្បាប់ស្តីពីសារពើពន្ធ(ចសព) និងបូកបន្ថែមប្រាក់រំដោះពន្ធលើប្រាក់ចំណេញ១%(ភាគរយ) លើតម្លៃសំណង់និងដីតាមមាត្រា២៨ នៃចសព។ ទន្ទឹមនឹងនេះ ម្ចាស់សំណង់ក៏មានកាតព្វកិច្ចបង់ប្រភេទពន្ធផ្សេងៗទៀត តាមច្បាប់ជាធរមានផងដែរ។

ករណីម្ចាស់សំណង់មិនអនុវត្តតាមសេចក្តីជូនដំណឹងនេះ នឹងទទួលរងការកំណត់ពន្ធឡើងវិញ ស្របតាមមាត្រា១១៦ មាត្រា១១៧ រួមទាំងទោសទណ្ឌតាមមាត្រា១២៨ មាត្រា១៣០ មាត្រា១៣១ មាត្រា១៣២ និងមាត្រា១៣៣ នៃចសព។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីជាម្ចាស់សំណង់បុរី ផ្ទះល្វែង វីឡា ឬអគារសម្រាប់លក់ទាំងអស់ នឹងអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ជាក់ជាពុំខាន។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK1, TOUL KAUK, PHNOM PENH Phone: (855) 23 886 708/ Fax: (885) 23 886 700